**ការបង្កាអំពើប្រល័យពូជសាសន៍ : គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**

**វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រ**

**កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា**

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# ការពិត ការបង្ហាញ និងនយោបាយនៃការចងចាំ បន្ទាប់ពីអំពើប្រល័យពូជសាសន៍

**អាឡិច ហ៊ិនតុន**

នៅពេលដែលប្រជាជនកម្ពុជាពិភាក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ នៅអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហម ដែលបានធ្វើឲ្យប្រជាជនពីរលាននាក់ ក្នុងចំណោមប្រជាជនខ្មែរសរុប៨លាននាក់ស្លាប់បាត់បង់ជីវិត ចាប់ពីខែមេសាឆ្នាំ១៩៧៥ ដល់ខែមករាឆ្នាំ១៩៧៩ អ្នកទាំងនេះនឹកឃើញពីមធ្យោបាយជាច្រើននៃការបំផ្លិចបំផ្លាញនេះ ។ ការចងចាំនេះក្លាយទៅជាស្រមោលនិងបទខគ្រិដ្ឋមួយ ។

ឆ្លាត ដែលជាមន្ត្រីរដ្ឋបាលខេត្តថ្នាក់ក្រោម និងជាអតីតសិស្សម្នាក់នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ បានរំឭកឡើងវិញនូវមរណភាពបងប្រុសរបស់គាត់ឈ្មោះ ស្រួន ។ សញ្ជប់សញ្ជឹងដោយទឹកមុខមាំ ឆ្លាត ជាមនុស្សម្នាក់ក្នុងចំណោមប្រជាជនទាំងនោះ ដែលប្រហែលជាអាចរៀនបានខ្ពង់ខ្ពស់ ប្រសិនបើបដិវត្តន៍ខ្មែរក្រហមមិនបានបំផ្លាញដំណើរជីវិតរបស់គាត់ទេនោះ ។ ភាពញញឹមបានឆ្លុះបញ្ចាំងពីជីវិតរបស់ ឆ្លាត ដែលតស៊ូដើម្បីភាពជោគជ័យ ហើយតែងតែព្រួយបារម្ភនិងព្យាយាមបំភ្លេចឲ្យអស់នូវការឈឺចាប់ទាំងប៉ុន្មាន ។ យើងក៏បាននិយាយជាច្រើនដងអំពីដំណើរជីវិតរបស់គាត់ដែលរួមបញ្ចូលពីរយៈពេលនៃការចងចាំខគ្រិដ្ឋកម្មមួយ ។

បុសគល់នៃបទពិសោធន៍ក្នុងសង្គមវិស្សកម្ម ខ្មែរក្រហមបានធ្វើការឃោសនាអំពីការឈ្លានពានពីអតីតកាលដើម្បីស្វែងរកវិធី ក្នុងការលុបបំបាត់អ្វីៗដែលជាកម្មែលរបស់មូលធននិយម “ឯកជននិយម” និងវណ្ណៈជិះជាន់ ។ ការឃោសនានេះកាន់តែរីករាលដាលខ្លាំងឡើងថែមទៀត ។ និយាយឲ្យចំខ្មែរក្រហមសំដៅលើព្រះពុទ្ធសាសនា គ្រួសារ របនាសម្ព័ន្ធភូមិឃុំ សកម្មភាពសេដ្ឋកិច្ច និងការអប់រំសាធារណៈ (ទាំងអស់នេះជាស្ថាប័នសង្គមវប្បធម៌ដ៏សំខាន់ ដែលនាំទៅរកការផ្លាស់ប្តូរនូវការចងចាំមានលក្ខណជាផ្លូវការ ក្រៅផ្លូវការ និងជាទម្លាប់) ។ កាន់តែច្បាស់ជាងនេះ ខ្មែរក្រហមបានបំផ្លាញការចងចាំក្នុងសង្គមតាមរយៈការដុតសៀវភៅ ការវាយកម្ទេចបណ្ណាល័យ ការហាមប្រាមមិនឲ្យមានតន្ត្រីសម័យ ភាពយន្ត ប្រព័ន្ធផ្សព្វផ្សាយ របៀបស៊ីវិល័យ និងការបំផ្លិចបំផ្លាញវត្តអារាម ការកាត់បន្ថយ

ការប្រាស្រ័យទាក់ទងគ្នា ការលុបបំបាត់ពិធីបុណ្យតាមបែបប្រពៃណីនិងសាសនា ការបំបែកសមាជិកគ្រួសារឲ្យនៅដាច់ដោយឡែក ការស្លៀកពាក់ដូចៗគ្នា ការលុបបំបាត់ទ្រព្យសម្បត្តិឯកជន ដែលរួមមានរូបថត វត្ថុចងចាំ និងវត្ថុអនុស្សាវរីយ៍ផ្សេងទៀត ។

ជម្លោះអតីតកាលត្រូវបានបង្ហាញឲ្យឃើញជាលើកដំបូង នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច ដោយធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងទៅនៅជនបទ បង្ខំប្រជាជនឲ្យចាកចេញពីផ្ទះដោយមិនបានប្រកាសឲ្យដឹងមុន ធ្វើឲ្យប្រជាជនរាប់រយពាន់នាក់កកស្ទះនៅលើវិថីនានាដែលធ្វើដំណើរចេញពីភ្នំពេញនិងពីទីរួមខេត្ត ។ ភាពច្របូកច្របល់ ការធ្វើដំណើរដោយគ្មានទិសដៅច្បាស់លាស់ឆ្លងកាត់វត្តអារាម សាលារៀន រោងកុន ភោជនីយដ្ឋាន សួនខ្ទឡាន ផ្លូវនានា ផ្ទះដែលមានរបៀបរៀបរយទីក្រុងត្រូវបានបំភ្លេចចោល ក្រដាសប្រាក់ដែលគ្មានតម្លៃប៉ើងរសាត់ទៅតាមខ្យល់ រថយន្តទំនើបគ្មានសាំងចាក់ អាហារផ្អូមដោយសារកម្តៅថ្ងៃ សៀវភៅជាច្រើនដែលមិនអាចយកទៅជាមួយបាន មនុស្សចាស់ជរានិងជនពិការដែលមិនអាចទ្រាំទ្រនឹងការធ្វើដំណើរបាន ។ ទាំងអស់នេះហើយ ដែលធ្វើឲ្យប្រជាជនគ្រប់រូបនៅតែចងចាំពីអតីតកាលដ៏ឈឺចាប់ ដែលខ្លួនបានជួបប្រទះកន្លងមក ។

នៅក្នុងសង្គមបដិវត្តន៍ថ្មី ប្រជាជនគ្រប់រូបត្រូវតែដើរតាមមាគ៌ាបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ ប្រៀបដូចជាការដំដែកដែលខ្មែរក្រហមហៅថា «លត់ដំ» ។ ប្រជាជនជម្លៀសម្នាក់បានពន្យល់ថាប្រយោគដែលគួរឲ្យភ័យខ្លាចនោះគឺ «លត់ដំ» ។ «លត់» មានន័យថា ដែកមួយប្រភេទដែលគេយកទៅដាក់ក្នុងភ្លើងឲ្យឡើងពណ៌ក្រហមនិងទន់ដើម្បីងាយស្រួលដំ ។ ចំណែក «ដំ» មានន័យថាដំដោយញញួរគឺយកដែកដែលដុតឡើងពណ៌ក្រហមទៅដាក់លើទ្រនាប់ ហើយវាយឲ្យទៅជាបែបសណ្ឋានណាមួយដែលយើងចង់បាន ។ «លត់ដំ» បានពិពណ៌នាពីវិធីសាស្ត្រដែលប្រជាជនគិតថាជាការរៀបចំឡើង ដោយអង្គការដើម្បីប្រែក្លាយឲ្យទៅជាប្រទេសកុម្មុយនីស្តពិតប្រាកដនៅថ្ងៃអនាគត ។

ការចងចាំត្រូវបានផ្លាស់ប្តូរក្នុងអំឡុងពេលនៃដំណើរការគ្រប់គ្រង ដើម្បីតម្រង់ទិសទៅតាមគោលគំនិតរបស់អង្គការដែលកែប្រែអតីតកាលឲ្យក្លាយទៅជាបដិវត្តន៍ក្រហមឆ្អិនឆ្អៅ ។ ការចម្លងទ្រឹស្តីរបស់ម៉ៅដើម្បីភ្ជាប់ជាមួយទ្រឹស្តីព្រះពុទ្ធសាសនា ដែលបានអប់រំពីដំណើរជីវិតនិងការប្រតិបត្តិតាមផ្លូវធម៌ ខ្មែរក្រហមចង់និយាយសំដៅទៅលើពាក្យ «កង់ប្រវត្តិសាស្ត្រ» ដែលគ្រប់គ្រងប្រទេសតាមច្បាប់ធម្មជាតិ និងដែលគេយល់ដឹងតាមរយៈ «វិទ្យាសាស្ត្រ» របស់ម៉ាកឡេនីនដើម្បីយកមកអនុវត្ត និងកែប្រែកម្ពុជាឲ្យក្លាយទៅជាប្រទេសកុម្មុយនីស្ត និងកម្ទេចចោលនូវអ្វីដែលរាំងស្ទះដល់កិច្ចការរបស់ខ្លួន ។ ចក្ខុវិស័យពីអតីកាលបានបង្ហាញយ៉ាងច្បាស់នៅក្នុងសុន្ទរកថារបស់ ប៉ុល ពត ធ្វើឡើងនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ ក្នុងទិវារំឭកខួបអនុស្សាវរីយ៍លើកទី១៧របស់បក្សកុម្មុយនីស្តកម្ពុជា ។ សុន្ទរកថាមិនត្រឹមតែប្រកាសជាសាធារណៈ ស្តីពីវត្តមានដំបូងរបស់បក្សកុម្មុយនីស្តកម្ពុជា និង ប៉ុល ពត ជាមេ

ដឹកនាំបក្សប៉ុណ្ណោះទេ ថែមទាំងបានរៀបរាប់ពីប្រវត្តិនៃចលនាតស៊ូបដិវត្តន៍ ក្នុងប្រទេសកម្ពុជាដែលធ្លាក់ចូលទៅក្នុងដំណាក់កាល "ទាសភាព" "សក្តិភូមិ" និង "សក្តិភូមិ-នាយទុននិយម" ដោយសារតែខ្វះ"គោលជំហរនយោបាយ" ។ គោលនយោបាយនេះបានបង្ហាញការពិត ពេលដែល ប៉ុល ពត ប្រកាសនៅឯសន្និបាតបក្សកុម្មុយនីស្តកម្ពុជាលើកទី១ ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី២៨-៣០ ខែកញ្ញា ឆ្នាំ១៩៦០ ដោយមានអ្នកបដិវត្តន៍ចំនួន២១រូបលាក់ខ្លួននៅក្នុងបន្ទប់សម្ងាត់មួយ ក្នុងស្ថានីយរថភ្លើង ក្នុងក្រុងភ្នំពេញ ។

ការយល់ដឹងតាមរយៈ "ការវិភាគបែបវិទ្យាសាស្ត្រ" នៃវិវាទនៅក្នុងសង្គមកម្ពុជារវាង "ប្រជាជនកម្ពុជានិងចក្រពត្តិនិយម ជាពិសេសចក្រពត្តិអាមេរិក" និងជម្លោះវណ្ណៈ (ជាពិសេស អ្នកមូលធននិយមនិងម្ចាស់ដី) បក្សអាចបង្កឲ្យមានអណ្តាតភ្លើងបដិវត្តន៍ ប្រៀបដូចជា "ចំបើងនៅក្នុងវាលស្រែនារដូវក្តៅ" ។ ផ្តើមចេញពីចំណុចនេះ ប៉ុល ពត បានថ្លែងថា សង្គ្រាមរីករាលដាលពេញប្រទេស ហើយចលនាបដិវត្តន៍នឹងវាយរំលំរបបសាធារណរដ្ឋខ្មែរ និងសហរដ្ឋអាមេរិក ។ គ្រាន់តែខ្សែបន្ទាត់តែមួយអាចធ្វើឲ្យខ្មែរក្រហមទទួលជ័យជម្នះបាន ដូច្នេះ បក្សក៏អាចដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅកាន់រដ្ឋកុម្មុយនីស្តជ្រាលជ្រៅមួយយ៉ាងឆាប់រហ័សផងដែរ ។

ការសម្រេចបាននូវគោលដៅនេះ តម្រូវឲ្យប្រទេសមានការចូលរួមពីអ្នកបដិវត្តន៍ថ្មីដែលឆ្លងកាត់ការលត់ដំការងារពលកម្មជាទម្ងន់ ការប្រជុំទិតៀន ការបើកវគ្គនយោបាយនិងការអប់រំសតិអារម្មណ៍ជាប្រចាំ ដើម្បីធ្វើឲ្យមានការយល់ដឹងកាន់តែជ្រៅជ្រះខាងផ្នែកនយោបាយ ហើយស្របទៅនឹងគោលនយោបាយរបស់បក្សនិងប្រវត្តិសាស្ត្រទៀតផង ។ ចំណុចទាំងនេះបញ្ជាក់ពីភាពដែលមិនអាចអូសទាញខ្លួនគេឲ្យធ្លាក់ទៅក្នុងអំពើ "ពុករលួយ" ដូចកាលពីអតីតកាលបានទេ ។ ជាឧទាហរណ៍ ការបរិយាយដ៏វែងអន្លាយរបស់អ្នកដែលនៅរស់រានមានជីវិតម្នាក់ អំពីការត្អូញត្អែរពីលក្ខខណ្ឌរស់នៅលំបាក ការមិនមានឱកាសសម្រាក ការប្រព្រឹត្តកំហុសឆ្គងនៅក្នុងការងារ ឬការទៅធ្វើការងារមិនបានខ្ជាប់ខ្ជួន ដែលទាំងអស់នេះ ខ្មែរក្រហមនិយាយថាជា"ជំងឺសតិអារម្មណ៍" ។ ប្រសិនបើជំងឺនេះជាជំងឺរ៉ាំរ៉ៃ ឬមិនអាចព្យាបាលឲ្យជាសះស្បើយឆាប់ទេនោះ វិធីព្យាបាលគឺសម្លាប់ចោល ។ ការសម្លាប់ជាវិធីមួយដែលធ្វើឡើងដើម្បីលុបបំបាត់នូវការចងចាំពីអតីតកាលដែលប្រឆាំងនឹងបដិវត្តន៍ ។

ឆ្លាត ជក់បារីរួចនិយាយប្រាប់ខ្ញុំអំពីរឿងរ៉ាវក្រុមគ្រួសាររបស់គាត់ ដែលធ្វើដំណើរប្រជ្រៀតគ្នាចាកចេញពីទីក្រុងភ្នំពេញក្រោមកម្តៅថ្ងៃស្ទើរឆេះ និងការធ្វើដំណើរដែលអាចដើរទៅមុខបានតែមួយម៉ែត្រប៉ុណ្ណោះក្នុងរយៈពេលពីរម៉ោង ។ នៅតាមផ្លូវ ខ្មែរក្រហមបានដកយកយកនាឡិកាដៃ សញ្ញាប័ត្រ និងសម្លៀកបំពាក់របស់គាត់ ។ នៅពេលនោះ បងថ្លៃរបស់ ឆ្លាត ជាអតីតមន្ត្រីយោធាម្នាក់បានបង្ហាញពីអត្តសញ្ញាណរបស់ខ្លួន ហើយក៏ត្រូវទាហានខ្មែរក្រហមនាំយកទៅ ដែលចាប់តាំងពីពេលនោះមក គាត់

មិនដែលឃើញបងថ្លៃគាត់ត្រឡប់មកវិញទេ ចំណែកជីតារបស់គាត់ស្លាប់ ហើយត្រូវបានកប់នៅតាមចិញ្ចើមផ្លូវ ដែលមានតែធូបធ្វើជាសញ្ញាសម្គាល់ប៉ុណ្ណោះ។ ពីដំបូង ឆ្នាត បានហុចបារីឲ្យខ្ញុំមួយដើម តែខ្ញុំបដិសេធ។ គាត់ញញឹមរួចនិយាយបន្តថា គាត់ចាប់ផ្តើមជក់បារីដំបូង គឺនៅពេលដែលខ្មែរក្រហមបញ្ជូនគាត់ឲ្យទៅដឹកលាមកមនុស្សពីបង្គន់មកធ្វើជី។ ឆ្នាត រៀបរាប់ថា «ក្លិនលាមកសាយភាយពេញខ្លួន ហើយបារីអាចកាត់ក្លិនស្អុយបាន។ ខ្ញុំបន្តជក់រហូត ទោះបីជាខ្ញុំឈប់ធ្វើការនៅទីនោះក៏ដោយ។ ខ្ញុំមិនដែលបានហូបផ្អែតទេ ប៉ុន្តែនៅពេលដែលខ្ញុំជក់បារី វាអាចជួយកាត់បន្ថយការស្រេកឃ្លានរបស់ខ្ញុំបាន» ។ គាត់ជក់បារី ពីព្រោះតែខួរក្បាលរបស់គាត់ស្មុគស្មាញ នៅពេលគាត់គិតពីរឿងរ៉ាវនៅក្នុងសម័យខ្មែរក្រហម ហើយការជក់បារីធ្វើឲ្យគាត់បានធូរស្រាលក្នុងចិត្ត។ នៅពេលដែល ឆ្នាត រំឭកដល់ព្រឹត្តិការណ៍នេះឡើងវិញ ការចងចាំទាំងប៉ុន្មានរបស់គាត់ ប្រៀបបានការជក់បារី ដែលទីបំផុតនៅសល់តែផេះផង់ប៉ុណ្ណោះ។

បន្ទាប់ពី ឆ្នាត ចេញពីធ្វើការនៅសាលាខេត្ត យើងតែងតែជួបគ្នាជារៀងរាល់ល្ងាចនៅផ្ទះមិត្តភក្តិម្នាក់។ ក្រោមពន្លឺភ្លើងអគ្គិសនីព្រាលៗ យើងអង្គុយនៅជុំវិញតុមូលដែលមានទៀនមួយដើមនិងភ្លើងបារីរបស់ ឆ្នាត ដែលជះពន្លឺអាចឲ្យយើងមើលឃើញពីរូបរាងនិងស្រមោលរបស់គាត់ជាប់នៅនឹងជញ្ជាំង។ នៅយប់នោះ ឆ្នាត បាននិយាយប្រាប់ខ្ញុំជាលើកដំបូងថា ក្នុងអំឡុងពេលដែលខ្មែរកំពុងធ្វើបន្សុទ្ធកម្មនៅឆ្នាំ១៩៧៧ បងប្រុសរបស់គាត់ក៏ត្រឡប់មករស់នៅវត្តភ្នំប្រុស។ នៅពេលអ្នកភូមិដឹងថាក្រុមគ្រួសាររបស់គាត់គឺជាអ្នកទីក្រុង ហើយបងប្រុសរបស់គាត់ឈ្មោះ ស្រួន ធ្លាប់ធ្វើការនៅក្រុមហ៊ុននីហរ័ណអាហរ័ណ ក្រុមគ្រួសាររបស់ ឆ្នាត ក៏វិលត្រឡប់ទៅរស់នៅភូមិកំណើតរបស់ឪពុកម្តាយវិញ។ កំពុងនិយាយប្រកបដោយសំឡេងទន់ភ្លន់ គាត់ក៏ឈប់មួយស្របក់ ហើយគោះកម្ទេចបារីចេញ ហើយបន្តថា បងប្រុសគាត់ ស្រួន ត្រូវខ្មែរក្រហមនាំយកទៅកាន់វត្តមួយដែលត្រូវបានប្រែក្លាយឲ្យទៅជាមណ្ឌលសម្លាប់វិញ។

ពីដំបូងយើងឮថា រថយន្តបានមកដឹកប្រជាជនចេញពីសហករណ៍ ដែលនៅជាប់គ្នាទៅរស់នៅ «ភូមិថ្មី» ។ ក្រោយមកក៏មានពាក្យចចាមអារ៉ាមថា ប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅសម្លាប់។ រថយន្តជាច្រើនគ្រឿងបានមកដល់ភូមិរបស់ខ្ញុំ ដោយមិនបានប្រាប់ឲ្យដឹងជាមុន។ ប្រជាជនត្រូវបានដឹកចេញនៅពេលថ្ងៃ។ យើងដឹងថា ដើមឆ្នាំ១៩៧៥ ជាពិសេសអ្នកដែលខ្ជិលធ្វើការងារឬមិនអាចធ្វើការធ្ងន់បាន ត្រូវខ្មែរក្រហមបញ្ជាឲ្យទៅរស់នៅភូមិថ្មី។ បងរបស់ខ្ញុំឈ្មោះ ស្រួន មិនត្រូវបានហៅឲ្យទៅធ្វើការងារទេ ព្រោះគាត់មានជំងឺនិងមិនអាចធ្វើការធ្ងន់ៗបាន គាត់ស្ទើរតែមិនជឿថាគាត់មានសំណាងល្អទេ។ ឆ្នាត និយាយបន្តទៀតថា «ខ្ញុំពិតជាសំណាង ពីព្រោះខ្ញុំបានសាងល្អពីជាតិមុន បានជាខ្ញុំគេច

ផុតពីស្លាប់ និងថាប្រជាជនទាំងនោះមិនត្រូវបាននាំទៅកាន់កន្លែងថ្មីទេ អ្នកទាំងនោះត្រូវបានសម្លាប់រួចហើយបោះសាកសពចោល» ។

នៅម៉ោង៨យប់នោះ បង ស្រួន នៅតែមិនទាន់ត្រូវបានហៅឈ្មោះនៅឡើយ ។ គាត់ទើបតែនិយាយថា «ខ្ញុំរួចផុតពីគ្រោះថ្នាក់ ហើយខ្ញុំមិនស្លាប់ទេ» ស្រាប់តែពេលនោះ សៀង ជាប្រធានភូមិបានមកគោះទ្វារហើយប្រាប់បង ស្រួន ថា «ប្រមូលអីវ៉ាន់របស់ឯងទៅ រថយន្តនឹងមកដឹកទៅភូមិថ្មី ។ បង ស្រួន ឈប់និយាយ ហើយអង្គុយនៅលើគ្រែទាំងអារម្មណ៍ភ័យតក់ស្លុត និងគិតអំពីហេតុការណ៍ដែលនឹងកើតឡើងចំពោះគ្រួសាររបស់គាត់ ។ នៅទីបញ្ចប់ គាត់និយាយថា «ដូច្នេះឈ្មោះរបស់ខ្ញុំនៅក្នុងបញ្ជីដែរ» ។ ខ្ញុំ (ឆ្លាត) សង្ស័យថា ច្បាស់ជាមាននរណាម្នាក់ដែលជាបងប្អូនសាច់ឆ្ងាយរបស់ខ្ញុំ ជាភ្នាក់ងាររបស់ខ្មែរក្រហម ដែលបានឲ្យគេដាក់ឈ្មោះបងប្រុសរបស់គាត់ជំនួសហើយមើលទៅ ។ បង ស្រួន បានប្រាប់ប្រពន្ធនិងកូនៗរបស់គាត់ឲ្យត្រៀមខ្លួនចេញដំណើរ ។ គាត់ផ្ដាំខ្ញុំថា «ថែរក្សាពុកនិងបងប្អូនរបស់យើងផង» ។ ចំពោះខ្ញុំៗមិនជឿថា ពួកគេនាំខ្ញុំទៅកន្លែងថ្មីទេ ។ ពួកគេនាំយើងយកទៅសម្លាប់ ។ អ៊ីៗនៅដដែល គ្មាននរណាម្នាក់ហ៊ាននិយាយអ៊ីទេ ។ ទាំងអស់គ្នា អាចត្រឹតែស្ងួរសំឡេងទឹកភ្នែងប៉ុណ្ណោះ ។

ប្រជាជនដែលមានឈ្មោះត្រូវបានបញ្ជាឲ្យទៅជួបជុំគ្នានៅក្បែរវត្ត ។ ស្រួន បានពកូនប្រុសពៅរបស់គាត់ការពារកុំឲ្យត្រូវភ្លៀងនិងប្រឡាក់ភក់ ហើយប្រពន្ធរបស់គាត់ក៏នៅទីនោះដែរ ។ យប់ណាស់ទៅហើយ ដូច្នេះខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនទាំងអស់សម្រាកនៅក្នុងវត្ត ។ កងឈ្លបបានការពារមិនឲ្យប្រជាជនចាកចេញពីបរិវេណនោះ ។ ក្មេងៗបានស្រែកយំដោយសារតែពួកវាឃ្លាន ។ ព្រឹកឡើងខ្មែរក្រហមបានដឹកប្រជាជនតាមរថយន្តជាច្រើនគ្រឿងចេញទៅ ។ បង ស្រួន និងគ្រួសាររបស់គាត់ត្រូវបានសម្លាប់នៅវត្តភ្នំប្រុស ។ ពីរ-បីថ្ងៃក្រោយមក សម្លៀកបំពាក់របស់គាត់ត្រូវបានយកមកចែកឲ្យប្រជាជននៅក្នុងភូមិ ដែលសម្លៀកបំពាក់ទាំងអស់នោះជារបស់ប្រជាជន ដែលត្រូវបានដឹកចេញទៅតាមរថយន្ត ។ ខ្ញុំឃើញពួកគេ (ខ្មែរក្រហម) ចែកសម្លៀកបំពាក់បងប្រុសខ្ញុំ ។

ការចងចាំរបស់ ឆ្លាត ចំពោះការស្លាប់របស់បងប្រុសគាត់ គឺជារឿងដែលហាក់ដូចជាកើតឡើងថ្មីៗ ពេលដែលយើងគិតទៅដល់ប្រជាជនរាប់លាននាក់នៅទូទាំងប្រទេសកម្ពុជា ដែលប្រឈមនឹងការសម្លាប់ ការឈឺចាប់ និងភាពភ័យរន្ធត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអ្នកទាំងអស់គ្នាសុទ្ធតែទទួលអារម្មណ៍ក្ដុកក្តួលបែបនេះ ។ ការចងចាំនិងអារម្មណ៍ឈឺចាប់នៅតែដក់ជាប់នៅក្នុងចិត្តប្រជាជនកម្ពុជា ខណៈពេលដែលមានអ្នកនិពន្ធជាច្រើនបានសរសេរពីរបបកម្ពុជាប្រជាធិបតេយ្យឡើងវិញ ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង ។

ជំពូកនេះនឹងសិក្សាស្វែងយល់ពីវិសាលភាពមួយចំនួននៃការចងចាំ ជាពិសេសប្រជាជននៅក្នុងរបបសាធារណរដ្ឋខ្មែរ និងវៀតណាមដែលគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យ ដោយបានផ្សារភ្ជាប់ភាពស្របច្បាប់របស់ខ្លួន ដើម្បីលាតត្រដាងពីអំពើហិង្សាកាលពីអតីតកាល ។ បន្ថែមពីនេះ យើងអាចមើលឃើញយ៉ាងទូលំទូលាយក្នុងការផ្លាស់ប្តូរវិធីសាស្ត្រនៃការចងចាំនៅក្នុងប្រទេសកម្ពុជា នៅអំឡុងពេលបោះឆ្នោតជាតិនៅឆ្នាំ១៩៩៣ ដែលគាំទ្រដោយអង្គការសហប្រជាជាតិ ។ ពេលនោះ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានរីកដុះដាលឡើងនៅក្នុងប្រទេសកម្ពុជា និងចាប់ផ្តើមពិភាក្សាទៅលើប្រធានបទនៃការផ្សះផ្សា សិទ្ធិមនុស្ស និងយុត្តិធម៌ ដែលជានិច្ចកាលត្រូវបានផ្សារភ្ជាប់ទៅនឹងទ្រឹស្តីព្រះពុទ្ធសាសនា ដើម្បីជាការចងចាំពីអំពើប្រល័យពូជសាសន៍ក្នុងអតីតកាល ។ ការផ្លាស់ប្តូរនេះអាចឲ្យយើងមើលឃើញម្តងទៀតជាមួយនឹងការកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហម ដែលគាំទ្រដោយអង្គការសហប្រជាជាតិ នៅខែកក្កដា ឆ្នាំ២០០៦ ។ បន្ទាប់ពីមានការពិភាក្សាពីភាពពិតនៃការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែរ ស្តីពីចំណេះដឹង អំណាច និងការចងចាំ ខ្ញុំក៏ពិចារណាអំពីព្រះពុទ្ធសាសនាដែលបានផ្សារភ្ជាប់គ្នា និងដូនកាលមានលក្ខណៈដោយឡែកជាមួយនឹងការពិភាក្សាថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ។

## ជ័យជម្នះនិងភាពស្របច្បាប់

នៅខែមករា ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមឈ្លានពានចូលប្រទេសកម្ពុជា ខ្មែរក្រហមបានបែកបាក់ខ្ចាត់ខ្ចាយ ហើយការចងចាំក៏បានផ្លាស់ប្តូរម្តងទៀត ។ ផ្លូវថ្នល់នានាក្នុងប្រទេសកម្ពុជាពោរពេញទៅដោយមនុស្ស ដែលមួយចំនួនបានស្លាប់ បាត់បង់ផ្ទះសម្បែង ខ្លះកំពុងស្វែងរកជម្រកថ្មី ហើយខ្លះទៀតកំពុងធ្វើដំណើរទៅព្រំដែននិងកន្លែងផ្សេងៗ ដែលខ្លួនមិនធ្លាប់បានស្គាល់ពីមុន ។

ប្រជាជនជាច្រើនក៏ដូចជា ឆ្លាត ដែរ ពួកគេគ្មាននៅសេសសល់អ្វីទាំងអស់ ហើយត្រូវប្រឈមមុខនឹងបញ្ហាជាច្រើន ថាតើខ្លួនត្រូវរស់នៅនិងរៀបចំជីវិតដោយរបៀបណា ។ នៅទីបញ្ចប់ ឆ្លាត បានទទួលការងារធ្វើជាគ្រូបង្រៀន ។ នៅដើមពោធិ៍មួយដើម ភូមិនេះមានទីតាំងនៅក្បែរវត្តភ្នំប្រុសក្នុងខេត្តកំពង់ចាម ដែលគ្មាននៅសេសសល់អ្វីក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ហើយអតីតប្រជាជនដែលធ្លាប់រស់នៅក្នុងភូមិបានវិលត្រឡប់មកផ្ទះរបស់ខ្លួនវិញ ។ ដូនពេលអ្នកទាំងពីរកំពុងជួបជុំគ្នា ធ្វើឲ្យពួកគាត់នឹកឃើញអតីតកាលដ៏គួរឲ្យរន្ធត់ ៖ មានរណ្តៅសាកសពជាច្រើន អណ្តូងទឹកនៅក្នុងភូមិពេញដោយសាកសព ហើយខ្យល់បក់បានជះក្លិនស្អុយចេញពីវត្ត ។ អ្នកទាំងនេះបានរំឭកពីអ្វីដែលខ្លួនដឹងច្បាស់ថា ដីស្រែចម្ការបច្ចុប្បន្នជារបស់គាត់ ហើយវាក៏នៅជាមួយនឹងវាលពិឃាតដែរ ព្រោះនៅពេលដែលគាត់ភ្ជួររាស់ម្តងៗ ឆ្អឹងនិងសម្លៀកបំពាក់របស់សាកសពតែងតែជាប់ជាមួយនង្គ័លជានិច្ច ។

នៅទីក្រុងភ្នំពេញ អ្នកថតរូបជនជាតិវៀតណាមពីរនាក់ដែលជាអ្នកអមដំណើរកងទ័ពឈ្លានពាន បានដើរតាមក្លិនស្អុយ រហូតទៅដល់បរិវេណនៃគុកទួលស្លែង ។ អ្វីដែលអ្នកទាំងនោះបានរកឃើញនៅខាងក្នុង គឺទិដ្ឋភាពដ៏គួរឲ្យខ្ពើមរអើម ។ អ្នកភូមិពោធិ៍ក៏បានរកឃើញថា ៖ មានបុរសជាច្រើនត្រូវបានសម្លាប់ដោយអាវុធបំពង់ក សាកសពមួយចំនួននៅជាប់ច្រវាក់ភ្ជាប់ទៅនឹងគ្រែដែក ហើយដេកនៅក្នុងថ្លុកឈាម និងឧបករណ៍ធ្វើទារុណកម្មជាច្រើន ដូចជាខ្នោះ ខ្សែតី និងបន្ទប់ដាក់អ្នកទោសតូចៗ ។ ភ្លាមៗនោះ ក្រុមអ្នកស្រាវជ្រាវបានរកឃើញកន្លែងលាក់ឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ដែលរៀបតាមលំដាប់ចាប់ពីរូបថតរហូតដល់ចម្លើយសារភាព ។

នៅអំឡុងពេលនៃការផ្លាស់ប្តូរនេះ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលទើបតែបង្កើតថ្មីក៏បានជួបប្រទះនូវបញ្ហាជាច្រើន រាប់ចាប់ពីផ្នែកសេដ្ឋកិច្ចរហូតដល់ហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតក្នុងស្ថានភាពខ្ទេចខ្ទាំនិងគ្រោះទុរ្ភិក្ស ។ ពេលនោះ របបថ្មីនេះក៏ទទួលរងនូវបញ្ហាខាងផ្នែកច្បាប់ផងដែរ ។ រដ្ឋាភិបាលនៃរបបនេះ ដឹកនាំដោយលោក ហេង សំរិន មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រទេសវៀតណាម ដែលបានបញ្ជូនកងទ័ពចំនួន១៥ម៉ឺននាក់ដើម្បីឈ្លានពាន និងប្រើអំណាចគ្រប់គ្រងលើរបបថ្មីនេះ ។

ក្នុងពេលដែលគំនិតជួយផ្តួចផ្តើមរបស់វៀតណាមក្នុងការផ្តួលរំលំរបបខ្មែរក្រហម ធ្វើឲ្យប្រជាជនកម្ពុជាជាច្រើននៅមានមន្ទិលសង្ស័យចំពោះប្រទេសមួយនេះ ដែលជាសត្រូវប្រវត្តិសាស្ត្រ និងដែលប្រជាជនកម្ពុជាជឿជាក់ថា មានចេតនាជាយូរយារមកហើយ ក្នុងការលេបយកទឹកដីកម្ពុជា ។ ប្រជាជនជាច្រើននៅតែមានការសង្ស័យថា របបថ្មីនេះប្រហែលជាដូចរបបកម្ពុជាប្រជាធិបតេយ្យដែរ ព្រោះទាំងអ្នកសង្គមនិយម និងមនុស្សមួយចំនួនដែលជាមន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលរួមមាន ហេង សំរិន និង រដ្ឋមន្ត្រីការបរទេសរបស់គាត់គឺលោក ហ៊ុន សែន ដែលត្រូវតែងតាំងជានាយករដ្ឋមន្ត្រីនៅឆ្នាំ១៩៨៥ គឺជាអតីតខ្មែរក្រហម ដែលបានរត់គេចពីរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលនៃការបោសសម្អាតរបស់ខ្មែរក្រហម ។ ការមន្ទិលសង្ស័យទាំងនេះត្រូវបានឃោសនាឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានប្រកាសពីអ្នកសង្គមនិយមគួរឲ្យភ័យខ្លាចនៃរបបមុន ។ នៅទីបំផុត រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានគំរាមកំហែងកាន់តែខ្លាំងឡើងពីក្រុមអ្នកតស៊ូ និងកងទ័ពខ្មែរក្រហមដែលបង្កើតឡើងថ្មីៗ បន្ទាប់ពីការធ្វើដំណើរក្នុងស្ថានភាពដ៏លំបាកមកដល់ព្រំដែនថៃ ។ ក្រុមអ្នកតស៊ូទាំងនេះត្រូវបានគាំទ្រដោយបរទេសដែលផ្តោតសំខាន់ទៅលើនយោបាយសង្គ្រាមត្រជាក់ ជាជាងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

ការបង្កើតច្បាប់ត្រូវបានរួមបញ្ចូលជាមួយនឹងនយោបាយ ដូចដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានរៀបរាប់ពីរឿងរ៉ាវពីអតីតកាល ដែលនេះធ្វើឲ្យមានភាពស្របច្បាប់ទាំងនៅក្នុងស្រុកនិងនៅ

បរទេស ។ អំពើប្រល័យពូជសាសន៍បានឈរនៅចំកណ្តាលនៃប្រវត្តិសាស្ត្រ ។ នយោបាយថ្មីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានលាតត្រដាងពីការដឹកនាំមហាលោភផ្តេះមហាអស្ចារ្យរបស់ ប៉ុល ពត, អៀង សារី និង ខៀវ សំផន ។ ដោយការអនុវត្តយ៉ាងខ្ជាប់ខ្ជួនរបស់អ្នកកាន់លទ្ធិម៉ៅ ដែលដើរតាមមាគ៌ាសង្គមនិយម បានធ្វើឲ្យរឿងរ៉ាវនេះមានដំណើរការទៅមុខ ។ អ្នកដើរតាមលទ្ធិនេះបានប្រព្រឹត្តខុសនិងបង្ខំឲ្យកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប រួមទាំងមេដឹកនាំរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (ដែលជាអតីតខ្មែរក្រហម) ឲ្យចូលរួមនៅក្នុងការឃោសនាពីភាពខុសឆ្គងនៃអំពើប្រល័យពូជសាសន៍ ។ ជាលទ្ធផល អតីតកម្មាភិបាលខ្មែរក្រហមភាគច្រើន ដែលរួមទាំងមន្ត្រី សាធារណរដ្ឋប្រជាមានិតកម្ពុជាផងមិនទទួលខុសត្រូវចំពោះព្រឹត្តិការណ៍ ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។

សេចក្តីថ្លែងការណ៍របស់អ្នកសង្គមនិយមនៅតែសំខាន់ ចំពោះការបរិយាយរឿងនេះដូចដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាលើកឡើង នៅពេលដែលចលនាបដិវត្តន៍ដណ្តើមបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ជ័យជម្នះនេះបានធ្វើឲ្យប្រទេសកម្ពុជារួចផុតពីនឹមអាណានិគមនិយម ចក្រពត្តិនិយម និងសក្តិភូមិនិយម ។ នៅក្នុងសុន្ទរកថាជាលើកដំបូងចំពោះការឈ្លានពាននេះ លោក ហេង សំរិន បានរៀបរាប់ពីអំឡុងពេលដែលបនប្រតិកិរិយា ប៉ុល ពត-អៀង សារី ដឹកនាំប្រទេសកម្ពុជាតាមផ្លូវខុស ដែលភ្លាមៗនោះជ័យជម្នះរបស់គេ ផ្តើមចេញជាគោលការណ៍ជម្លៀសអ្នកទីក្រុងទៅជនបទ បង្ខំប្រជាជនឲ្យរស់នៅជាសហករណ៍រួម លុបបំបាត់រូបិយវត្ថុ និងរិះគន់យ៉ាងខ្លាំងទៅលើការរស់នៅជាលក្ខណៈក្រុមគ្រួសារ និងជីវភាពរបស់អ្នកភូមិ ។ សកម្មភាពនេះជាសញ្ញាណបង្ហាញពីការសម្លាប់រង្គាលកាន់តែសាហាវឃោរឃៅនិងព្រៃផ្សៃ ដែលប្រព្រឹត្តដោយមនុស្សវ័យកណ្តាល ឬដោយពួកហ្វាស៊ីសហ៊ីទ្លែរនិយម ។ ត្រឡប់មកវិញ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានអះអាងថារបបនេះជាអ្នកបដិវត្តន៍ដ៏ពិតប្រាកដ ដែលមានការជួយជ្រោមជ្រែងពីវៀតណាម ជាបងប្អូនដែលបានរំដោះប្រជាជនឲ្យរួចផុតពីឋាននរក ។ រឿងរ៉ាវនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានប្រជាជនជាខ្នងបង្អែកអាចធានាថា ភាពភ័យរន្ធត់នៃរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចវិលត្រឡប់មកវិញឡើយ ។ ជាមួយនឹងការកើនឡើងនៃអ្នកបដិវត្តន៍ខ្មែរក្រហមនៅតាមព្រំដែន តួនាទីនេះមានសារសំខាន់យ៉ាងខ្លាំងចំពោះប្រជាជននៅតាមទីជនបទ ។

នៅខណៈដែលរដ្ឋាភិបាលនីមួយៗឲ្យនិយមន័យខ្លួនទៅលើពាក្យ អតីតកាលដែលស្រមើស្រមៃអនាគតកាល និងរបបថ្មី ជាពិសេសដូចជារបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានឡើងកាន់អំណាចដោយភាពស្របច្បាប់ ដែលនៅតែមានមន្ទិលសង្ស័យនោះ បានបូជាកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លាដើម្បីសម្រេចបាននូវការចង់បានរបស់ខ្លួន ។ យន្តការក្នុងការបង្កើតការពិតមានច្រើនបែបខុសៗគ្នា រាប់ចាប់ពីការចងក្រងបង្កើតច្បាប់អប់រំណែនាំដើម្បីបង្កើតបូជនីយដ្ឋាននានា ។តាមរយៈការបញ្ចូលស្ថាប័នផ្សេងៗ

គ្នា រដ្ឋាភិបាលអាចបង្កើតការសម្រេចចិត្តដ៏ពេញលេញមួយជា «ឧបករណ៍» ដើម្បីបំពេញគោលដៅជាយុត្តិសាស្ត្ររបស់ខ្លួន ដូចជាការរៀបរាប់ដេញដោលពីប្រជាជន ដែលជំរុញឲ្យការគ្រប់គ្រងនិងភាពស្របច្បាប់នេះកាន់តែមានភាពប្រសើរឡើង ។

យើងអាចមើលឃើញពីដំណើរការនេះ ក្នុងអំឡុងពេលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋាភិបាលបានប្រើប្រាស់ស្ថាប័នចម្រុះដែលធ្វើឲ្យរចនាសម្ព័ន្ធគ្រប់គ្រងមានភាពធូររលុង និងដើម្បីធ្វើឲ្យមានភាពស្របច្បាប់ ។ អ្វីដែលសំខាន់មួយទៀតនោះគឺការអប់រំ ព្រោះវាដើរតួនាទីជាអ្នករំឭកដល់ភាពសាហាវព្រៃផ្សៃនៃរបបកម្ពុជាប្រជាធិបតេយ្យ ចាប់តាំងពីខ្មែរក្រហមបានបោះបង់ចោលប្រព័ន្ធអប់រំជាផ្លូវការ ហើយប្រែក្លាយសាលារៀនជាច្រើនទៅជាមន្ទីរ គុក និងកន្លែងផ្ទុកសម្ភារៈ ។ នៅពេលនោះដែររបបកម្ពុជាប្រជាធិបតេយ្យមានការអប់រំតែនៅថ្នាក់ដំបូងប៉ុណ្ណោះ ព្រោះខ្មែរក្រហមជឿជាក់ថា ប្រព័ន្ធអប់រំក្នុងរបបមុនធ្វើឲ្យខូចខួរក្បាលក្មេងៗ ហើយថាការអប់រំដែលល្អបំផុតនោះគឺការបញ្ចូលមនោគមន៍វិជ្ជានយោបាយនិងការរៀនសូត្រតាមរយៈ «ការតស៊ូ» លើផ្នែកសេដ្ឋកិច្ចដែលជាមាគ៌ាសំខាន់ ។ ដូច្នេះយោងតាមសុន្ទរកថាម៉ៅនិយម ខ្មែរក្រហមបានប្រកាសថា «ដងចបគឺជាស្លាបប៉ាកា ហើយវាលស្រែគឺជាក្រដាស» ហើយប្រសិន«បើចង់បានបាក់អង់បាក់ឌុប ត្រូវទៅយកនៅទំនប់ប្រឡាយ» ។

## ការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍ក្នុងអតីតកាល

ភាពវិនាសហិនហោចនៃអតីតកាលក៏ជាសញ្ញាណរូបសាស្ត្រ នៃការខូចខាំសាលារៀននិងសម្ភារៈផ្សេងៗ ដែលជានិមិត្តរូបបញ្ជាក់ពីការបាត់បង់ដ៏ធំធេងរបស់កម្ពុជា (នៅក្រោមរបបខ្មែរក្រហម) ហើយនៅក្នុងករណីជាច្រើនតាមរយៈស្លាកស្នាមជញ្ជាំង ដែលធ្លុះធ្លាយដោយសារគ្រាប់កាំភ្លើង (ដែលបង្ហាញពីនិមិត្តរូបនៃអំពើហិង្សាពីអតីតកាលនិងគ្រោះថ្នាក់នាបច្ចុប្បន្នកាល) ។ ម្យ៉ាងវិញទៀត ការសិក្សាអប់រំបានបង្ហាញពីសមិទ្ធផលមួយ ក្នុងចំណោមសមិទ្ធផលធំៗជាច្រើនទៀតរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានស្តាបនាប្រព័ន្ធសាលារៀនយ៉ាងឆាប់រហ័ស ។ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៩ ក្នុងសុន្ទរកថាបុណ្យខួបរំឭកថ្ងៃនៃការផ្តើមឲ្យមានសាលារៀន សម្រាប់ឆ្នាំសិក្សា ១៩៧៩ដល់ឆ្នាំ១៩៨០ លោក ហេង សំរិន បានលើកពីប្រធានបទនានា ដោយសង្កត់ធ្ងន់ទៅលើអំពើប្រល័យពូជសាសន៍ដ៏ឃោរឃៅរបស់បន ប៉ុល ពត និង អៀង សារី ដែលហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិស័យអប់រំនិងការបង្ហាត់បង្រៀនត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ជាពិសេសការសម្លាប់អ្នកដែលបានទទួលការអប់រំខ្ពង់ខ្ពស់ក្នុងនោះមានសិស្ស និស្សិត និងគ្រូបង្រៀនជាដើម ។

សុន្ទរកថាខ្លីទាំងនេះត្រូវបានបញ្ចូលទៅក្នុងឯកសារបង្រៀន ដូចជានៅក្នុងសៀវភៅរៀនថ្នាក់ទីបួនដែលបោះពុម្ពដោយក្រសួងអប់រំក្នុងឆ្នាំ១៩៨៣ ។ សៀវភៅនោះមានរួមបញ្ចូលកំណាព្យដែលមាន

ចំណងជើងថា «ការឈឺចាប់របស់ប្រជាជនកម្ពុជានៅក្នុងអំឡុងពេលនៃរបប ប៉ុល ពត អៀង សារី» ដែលរចនាឡើងដោយមានគំនូរមួយ បង្ហាញពីប្តីប្រពន្ធមួយគូត្រូវបានសម្លាប់ ខណៈពេលដែលក្មេងប្រុសម្នាក់បានឃើញភាពរន្ធត់ ដែលបុរសម្នាក់កំពុងត្រូវបានព្យួរក ។ ដូចនៅក្នុងសៀវភៅអប់រំសីលធម៌ដែលបោះពុម្ពនៅក្នុងឆ្នាំ១៩៨៤ ក៏មានបញ្ចូលមេរៀនស្តីពីបដិវត្តន៍ថ្មី បានផ្តល់ភាពសុខសាន្តទៅឲ្យប្រជាជន ដោយមានភ្ជាប់ជាមួយរូបគំនូរបង្ហាញពីភាពសប្បាយរីករាយរបស់ប្រជាជនក្នុងការអបអរសាទរចំពោះកងទ័ព និងបង្ហាញពីផែនការឧក្រិដ្ឋកម្មរបស់បន ប៉ុល ពត-អៀង សារី ក្នុងការបំបាត់ពូជសាសន៍ ក្នុងនោះមានភ្ជាប់រូបគំនូរប្រជាជនដែលត្រូវបានសម្លាប់នៅក្នុងរណ្តៅសាកសពដ៏ធំមួយ ដោយកម្មាភិបាលខ្មែរក្រហម ដែលមានស្នាមប្រឡាក់ឈាមជាប់នឹងចបនិងព្រនង់ ។ បន្ទាប់ពីរៀបរាប់រួច មានសំណួរជាច្រើនត្រូវបានលើកឡើងមកពិភាក្សានៅក្នុងថ្នាក់ ។ សំណួរទាំងនោះរួមមាន ៖

១) តើអំពើឧក្រិដ្ឋកម្មបែបណាដែលបន ប៉ុល ពត អៀង សារី ធ្វើមកលើប្រជាជនកម្ពុជា?

២) តើពួកវាបានសម្លាប់ប្រជាជនខ្មែរតាមវិធីណាខ្លះ?

៣) តើពួកបនទាំងនេះសម្លាប់ជនជាតិខ្មែរ ក្នុងគោលបំណងអ្វី?

ការបញ្ចូលមេរៀនទាំងអស់នេះនៅក្នុងកម្មវិធីសិក្សា បានផ្តល់នូវចម្លើយទៅឲ្យក្មេងអាយុ៥-៦ឆ្នាំ តាមរយៈការពិពណ៌នាពីអំពើសម្លាប់ដ៏សាហាវបំផុតរបស់ខ្មែរក្រហម ដូចជាការជីករណ្តៅធំៗ ប្រឡាយជ្រៅៗដើម្បីកប់ជនរងគ្រោះទាំងរស់ បន្ទាប់ពីអ្នកទាំងនោះបានទទួលរងទារុណកម្មយ៉ាងវេទនា ដោយចប ដំបង និងពូថៅ ។ សៀវភៅសិក្សាសរសេរថា ស្ត្រីនិងកុមារមិនត្រូវបានទុកជីវិត ដែលគោលបំណងរបស់ខ្មែរក្រហមគឺដើម្បីសម្លាប់និងបំផ្លាញប្រជាជនកម្ពុជា ដើម្បីឲ្យជាតិសាសន៍រលាយសាបសូន្យ ។ សៀវភៅសិក្សាបែបនេះគូសបញ្ជាក់ខុសគ្នាអំពីបន ប៉ុល ពត-អៀង សារី ថា អ្នកទាំងពីរមិនមែនជាជនជាតិខ្មែរ គឺជាសត្រូវដ៏គ្រោះថ្នាក់ក្នុងការបំផ្លាញពូជសាសន៍កម្ពុជានិងជាពួកកុម្មុយនីស្តប្រតិកិរិយា ។

តាមរយៈការអានសៀវភៅសិក្សាទាំងនេះ យើងអាចរកឃើញភាគច្រើនបំផុតអំពីការរៀបរាប់រឿងរ៉ាវដែលមានខ្លឹមសាររួមជាមួយរូបថតនិងផ្ទាំងគំនូរផ្សព្វផ្សាយ ដែលរូបភាពទាំងនេះផ្តោតសំខាន់អំពីការពិតនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដូចជាការពិពណ៌នាដដែលៗអំពីភាពសាហាវយង់ឃ្នងនិងអំពើឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយបនប៉ុលពត-អៀងសារី និងមហាសោកនាដកម្មរបស់ប្រជាជននិងការអះអាងថា បនប្រល័យពូជសាសន៍ទាំងនេះខ្វះលក្ខណៈជាខ្មែរ គឺសង្គមនិយមប្រតិកិរិយា និងការប្រកាសពីចំណងមិត្តភាពយូរអង្វែងកម្ពុជា-វៀតណាម ។ ការកោតសរសើរពីមហា ជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ និងដំណើរការជឿនលឿនរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបង្កើតបានសមិទ្ធផល ហើយនិងបង្ហាញយ៉ាងច្បាស់ពីសមិទ្ធផលរបស់កងទ័ព និងយោធានៃសាធារណ

ប្រជាមានិតកម្ពុជា ដែលបានការពារប្រជាជនឲ្យរួចផុតពីការវិលត្រឡប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អត្ថបទសម្រាប់ថ្នាក់ទី៨ បោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៨៨ ដែលខ្ញុំបានជួបនោះ គឺផ្តោតសំខាន់ទៅលើប្រធានបទទាំងអស់នេះ និងភាគច្រើនទៀតទាក់ទងនឹងអត្ថបទតាមលំដាប់រៀងៗគ្នានៅទួលស្លែងគឺ «ការធ្វើទារុណកម្មនៅទួលស្លែង» ជាមួយនឹងរូបភាពអ្នកទោស ដែលស្លាប់ទាំងជាប់ខ្នោះដែកនៅក្នុងថ្កុកឈាម និងឧបករណ៍ធ្វើទារុណកម្មផ្សេងទៀត ។

## ការចងចាំនូវរបបប្រល័យពូជសាសន៍នាអតីតកាល

ឥឡូវនេះយើងបានរកឃើញទំនាក់ទំនងមួយ ទៅនឹងផ្នែកផ្សេងទៀតនៃការពិតនិងការចងចាំរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ផ្ទុយគ្នានឹងការផ្តោតទៅលើការរៀបរាប់នៃសៀវភៅសិក្សារបស់សាលា ការចងចាំនៃរបបនេះ ដូចជានៅទួលស្លែង និងវាលពិឃាតជើងឯកបញ្ឆោកពីនិមិត្តរូបនះ ។

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលត្រូវបានសម្ពោធនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨០ ស្ថាបនាឡើងដើម្បីបង្កើតនូវអារម្មណ៍យថាភាព ដែលហាក់បីដូចជាយើងបានមើលឃើញពីទិដ្ឋភាពនោះមួយភ្លែត ។ អារម្មណ៍នេះកើតឡើងភ្លាមៗ និងពោរពេញដោយកម្លាំង ដែលបង្កប់អត្ថន័យសំខាន់លើអគារទី១ក្នុងចំណោមអគារទាំងបួន ដែលអ្នកទស្សនាបានជួបប្រទះ និងជាកន្លែងដែលអ្នកទស្សនាបានចូលទៅដល់ ហើយមានអារម្មណ៍ហាក់ដូចជានៅក្នុងបន្ទប់សួរចម្លើយ ដែលអ្នកទោសចុងក្រោយត្រូវបានសម្លាប់យ៉ាងសាហាវ និងស្នាមឈាមប្រឡាក់ជាប់ឥដ្ឋដែលមើលឃើញយ៉ាងច្បាស់ ។ បន្ទប់នីមួយៗរួមមានរូបថតដ៏ធំរបស់អ្នកទោស ដែលត្រូវបានសម្លាប់ បន្ទាប់ពីខ្មែរក្រហមបានបោះបង់ចោលមន្ទីរសន្តិសុខនេះដោយគ្មានបន្សល់ទុកអ្វីទាំងអស់ ។ អគារទីពីររួមមានរូបថតអ្នកទោស ព្យួរលើជញ្ជាំងបន្តគ្នា ដែលបានថតនៅពេលអ្នកទោសទាំងនោះមកដល់ទួលស្លែង ។ ទឹកមុខនៅក្នុងរូបថតនីមួយៗបង្ហាញពីអារម្មណ៍ស្ទើរតែគ្រប់ប្រភេទ ប៉ុន្តែរូបថតទាំងអស់នេះមើលទៅគួរឲ្យភ័យខ្លាច ។ ក្នុងនាមជាអ្នកទស្សនាដែលបានមើលឃើញរួចមកហើយនៅក្នុងអគារទី១ គឺដឹងយ៉ាងច្បាស់អំពីជោគវាសនារបស់អ្នកទាំងនោះ ។

នៅក្នុងអគារទីបី អ្នកទស្សនាបានរកឃើញបន្ទប់រៀន ត្រូវបានបែងចែកទៅជាបន្ទប់ឥដ្ឋតូចៗ ដែលមានអ្នកទោសត្រូវបានដាក់ខ្នោះ និងមានកេសគ្រាប់សម្រាប់ឲ្យអ្នកទោសបន្ទោរបង់ដោយខ្លួនឯង ។ វិន័យសន្តិបាលរបស់ខ្មែរក្រហមចំពោះអ្នកទោសបានសរសេរបិទនៅលើជញ្ជាំងអគារថា «អ្នកទោសត្រូវតែសុំការអនុញ្ញាតមុននឹងធ្វើអ្វីមួយ» ។ អគារចុងក្រោយគឺធ្វើឲ្យយើងនឹកឃើញដល់សារមន្ទីរបុរាណមួយ ដែលមានឧបករណ៍នៅក្នុងទូកញ្ចក់សេសសល់ពីរបបខ្មែរក្រហម ដោយរៀបចំជាជួរចាប់ពីឧបករណ៍ធ្វើទារុណកម្មរហូតដល់រូបសំណាករបស់ ប៉ុល ពត ដែលត្រូវបានស្ថាបនាឡើងនៅក្នុងបរិវេណនេះ ។ អគារ

នេះមានអត្ថបទសរសេរច្រើនជាងអគារផ្សេងទៀត ប៉ុន្តែក៏នៅមានរូបគំនូរមួយចំនួនបង្ហាញយ៉ាងច្បាស់ពីឧបករណ៍ដែលនៅសេសសល់និងរូបគំនូររបស់ខ្មែរក្រហមដែលគូរដោយ លោក វ៉ាន់ ណាត ដែលជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខនេះ ។ ទោះបីជាមានការរៀបចំដូចខាងលើរួចហើយក្តី ក៏រហូតមកដល់ពេលថ្មីនេះមានការតាំងពិព័រណ៍ ដែលគួរឲ្យចាប់អារម្មណ៍ខ្លាំងបំផុតនៅក្នុងបន្ទប់ចុងក្រោយ ដែលមានផែនទីប្រទេសកម្ពុជាទំហំ១២ម៉ែត្រការ៉េ តម្រៀបដោយលលាដ៍ក្បាលចំនួន៣០០ យកមកពីខេត្តនានានៅទូទាំងប្រទេសកម្ពុជាជាមួយផ្លូវទឹកដែលផាត់ពណ៌ក្រហមដូចឈាម ។

លលាដ៏ក្បាលទាំងនោះបានក្លាយជានិមិត្តរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ កន្លែងរំឭកវិញ្ញាណក្ខន្ធនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ដែលបានបើកសម្ពោធនៅឆ្នាំ១៩៨០ និងមានកន្លែងរំឭកវិញ្ញាណក្ខន្ធដទៃទៀតនៅទូទាំងប្រទេស រួមមានទីតាំងវាលពិឃាតនៅវត្តភ្នំប្រុសដែលត្រូវបានសាងសង់ឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៨៣ ។ លលាដ៏ក្បាលទាំងនោះជាតឹកតាងដែលបានភ្ជាប់ជាមួយសេចក្តីថ្លែងការណ៍ជាផ្លូវការស្តីពីការស្លាប់ ការបំផ្លិចបំផ្លាញ អំពើឃោរឃៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងគ្រោះថ្នាក់នៃការវិលត្រឡប់មកវិញនៃបន ប៉ុល ពត-អៀង សារី ។ រូបថតនៅទួលស្លែងក៏បង្ហាញនូវគោលបំណងស្រដៀងគ្នានេះដែរ ពីព្រោះថា ប្រជាជនកម្ពុជាបានដឹងយ៉ាងច្បាស់ពីជោគវាសនានៃរូបគំនូរប្រជាជន ដែលតាំងបង្ហាញនេះ ហើយដែលធ្វើឲ្យពួកគាត់នឹកឃើញឡើងវិញពីការឈឺចាប់ និងការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទួលស្លែងនិងបូជនីយដ្ឋានជាច្រើនទៀតក៏ជាភស្តុតាងនៃអំពើឧក្រិដ្ឋកម្មដែលបន ប៉ុល ពត បានប្រព្រឹត្តមកលើប្រជាជនស្លូតត្រង់ដែរ ។

ជាមួយនឹងមាគ៌ានយោបាយនេះ ការខ្វះខាតទស្សនវិស័យ គឺប្រៀបបាននឹងលលាដ៏ក្បាលចងរុំភ្នែក ។ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្សារភ្ជាប់ទៅនឹងការបាត់បង់ការចងចាំនិងវិចារណញ្ញាណ ។ អ្នកនៅរស់ជាច្រើនបានរំឭកពីរបបកម្ពុជាប្រជាធិបតេយ្យ ថាជាពេលមួយដែលប្រជាជនត្រូវផ្លាស់ប្តូរទម្លាប់របស់ខ្លួន ដូចជាការនិយាយស្តីនិងការរស់នៅប្រចាំថ្ងៃជាដើម ។ ប្រជាជនជាច្រើនបានខ្សឹបដាក់គ្នាថា “ដាំដើមគ” មានន័យថាមិននិយាយស្តី ។ មាគ៌ានយោបាយដែលខ្វះខាតទស្សនវិស័យគ្រប់គ្រងបានបណ្តាលឲ្យប្រជាជនជាច្រើនបាត់បង់សិទ្ធិសេរីភាពនិងកម្មសិទ្ធិផ្ទាល់ខ្លួន ។ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានភ្ជាប់ទៅនឹងការស្លាប់និងលលាដ៏ក្បាលចងរុំភ្នែកដ៏ច្រើនសន្ធឹកសន្ធាប់ តាមរយៈការរៀបរាប់ពីប្រវត្តិអ្នកបាត់ខ្លួននិងការនិទានអំពីខ្មែរក្រហមស៊ីថ្លើមជនរងគ្រោះ ការប្រើអំណាចក្នុងសង្គមដែលមនុស្សគិតថាវាជាអំពើព្រៃផ្សៃ ។ ជាការពិតណាស់ របបកម្ពុជាប្រជាធិបតេយ្យផ្សារភ្ជាប់ទៅនឹងការស្លាប់និងការបំបាត់ការចងចាំ ។

ខណៈដែលជនរងគ្រោះមើលមិនឃើញ ខ្មែរក្រហមបានអះអាងថា គេមើលឃើញទាំងអស់ ។ របបកម្ពុជាប្រជាធិបតេយ្យមានវិធីសាស្ត្រជាច្រើនដើម្បីស៊ើបការណ៍ ដូចជាការដាក់បណ្តាញសម្ងាត់សម្រាប់តាមដានរាល់ទង្វើ និងការនិយាយស្តីរបស់ប្រជាជនជាដើម ។ នៅក្នុងអត្ថបទនយោបាយ របបនេះត្រូវបានចាត់ទុកថា "មើលឃើញគ្រប់បែបយ៉ាង" និង"ដឹងពីអនាគត" ដែលប្រជាជនហៅថា "អង្គការភ្នែកម្នាស់" ។ ទស្សនវិស័យនេះបានកាត់ផ្តាច់ចេញពីការឃោសនានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលលើកឡើងពីការបំភិតបំភ័យ ការចុះខ្សោយ និងភាពល្ងង់ខ្លៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ទីតាំងនិងរូបភាពចំពីមុខ រួមជាមួយឧបករណ៍ដទៃទៀត គឺជាការស្វែងរកការពិតនិងការចងចាំ ដូចជា ថ្ងៃទី៧ ខែមករា "ថ្ងៃរំដោះ" និង ថ្ងៃទី២០ ខែឧសភា "ទិវាចងកំហឹង" ។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានឧបត្ថម្ភ ក្នុងការបោះពុម្ពនិងថតខ្សែភាពយន្តស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ និងការកាត់ទោសកំបាំងមុខ ប៉ុល ពត និង អៀង សារី ដោយតុលាការប្រជាជនបដិវត្តន៍នៅឆ្នាំ១៩៧៩ផងដែរ ។

## រឿងនិទានដែលមិនចុះសម្រុងគ្នា

ទោះបីមានរឿងនិទានដ៏លើសលប់និងមានស្ថាប័នជាច្រើននៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានលើកឡើងពីរបបកម្ពុជាប្រជាធិបតេយ្យក្តី ក៏អំណះអំណាងទាំងនោះមិនទាន់បានប្រមូលផ្តុំនៅឡើយទេ ។ ផ្ទុយទៅវិញ វាបានប្រឈមទៅនឹងបញ្ហាទាំងខាងក្នុងនិងខាងក្រៅ ដោយសារការបកស្រាយផ្ទុយគ្នានិងកម្រិតយល់ដឹងរបស់ប្រជាជន ។ ជាក់ស្តែង ការឃោសនាលើឆាកអន្តរជាតិ ស្តីពីមិត្តភាពកម្ពុជា-វៀតណាម ដែលឧទាហរណ៍នេះមិនអាចឲ្យ ឆ្លាត ឈប់ស្អប់ជនជាតិវៀតណាមបានទេ ព្រោះវាជាអារម្មណ៍ដែលប្រជាជនខ្មែរមួយចំនួនគិតថា វៀតណាមមើលងាយខ្មែរ និងមានបំណងចង់បានទឹកដីខ្មែរតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ននេះ ។ គាត់បានប្រាប់ខ្ញុំម្តងហើយម្តងទៀតថា "ខ្ញុំមិនអាចនិយាយបានថាខ្ញុំស្អប់វៀតណាមប៉ុណ្ណោះទេ" និងបានបន្ថែមការរិះគន់អំពីចរិតពុតត្បុតរបស់ជនជាតិវៀតណាមទៀតផង ។ ប្រទេសវៀតណាមគឺជាចំណាប់អារម្មណ៍សម្រាប់ជនជាតិខ្មែរដែលរស់នៅបរទេស ដែលបានចាត់ទុករបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ថាជាខែលនៃការគ្រប់គ្រងរបស់វៀតណាម ហើយកម្ពុជាត្រូវតែរំដោះខ្លួនពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានសម្ព័ន្ធភាពជាមួយសត្រូវវៀតណាមនេះ ។ រឿងនិទានទាំងនេះពាក់ព័ន្ធទៅនឹងការធ្វើប្រជាភិថុតិរបស់ខ្មែរក្រហម ដែលមានបំណងកសាងកម្លាំងរបស់ខ្លួនឡើងវិញ ។ ខ្មែរក្រហមបានរិះគន់ចំណងមិត្តភាពរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជានិងវៀតណាម ហើយបានចោទប្រកាន់ថា វៀតណាមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងប្រជាជន

កម្ពុជា និងប្រឌិតភ័ស្តុតាងផ្សេងៗដូចជាគុកទួលស្លែង និងជើងឯកជាដើម ។ គួរឲ្យសោកស្តាយ ជំហរប្រឆាំងនឹងវៀតណាមនេះត្រូវស្ថិតក្នុងដៃប្រទេសចិន ថៃ សហរដ្ឋអាមេរិក និងមហាអំណាចបស្ចិមប្រទេសដទៃទៀត ដែលចាត់ទុកប្រទេសកម្ពុជាជាមូលដ្ឋាននៃជម្លោះសង្គ្រាមត្រជាក់ក្នុងពិភពលោក ។ ប្រទេសទាំងនេះមិនគ្រាន់តែគាំទ្រខ្មែរក្រហមប៉ុណ្ណោះទេ ថែមទាំងអនុញ្ញាតឲ្យមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យមានកៅអីនៅអង្គការសហប្រជាជាតិ និងមិនអើពើការអំពាវនាវ សុំឲ្យមានតុលាការអន្តរជាតិសម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហមទៀតផង ។

ផ្ទុយមកវិញ ខ្មែរក្រហមបានប្រើភាពស្របច្បាប់ថ្មីនេះដើម្បីថ្លែងពីអតីតកាលរបស់ខ្លួន ។ អតីតមេដឹកនាំខ្មែរក្រហមបានធ្វើសុន្ទរកថាទៅកាន់អ្នកស្តាប់អន្តរជាតិ ដោយមិនត្រឹមតែបដិសេធថាខ្លួនមិនបានប្រព្រឹត្តអំពើឃោរឃៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចោទប្រកាន់វៀតណាមថាជាអ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍ថែមទៀត ។ ភ័ស្តុតាងរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានខ្មែរក្រហមបដិសេធថាជាការប្រឌិត ។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ វិទ្យុខ្មែរក្រហមបានផ្សាយថា គ្រោងឆ្អឹងនៅទួលស្លែង គឺជាផ្នែកមួយនៃសង្គ្រាមចិត្តសាស្ត្រ ដែលប្រព្រឹត្តដោយវៀតណាមប្រឆាំងនឹងកម្ពុជា ។ ប្រទេសកុម្មុយនីស្តវៀតណាមបានប្រមែប្រមូលលលាដ៏ក្បាល និងឆ្អឹងពីទីវាលកប់សាកសពនៅវៀតណាមខាងជើងនិងខាងត្បូង ដឹកតាមរថយន្តមកកម្ពុជា និងដាក់តាំងបង្ហាញនៅទួលស្លែង ដើម្បីធ្វើជាយុទ្ធនាការឃោសនាផ្នែកចិត្តសាស្ត្រសម្រាប់បិទបាំងពីអំពើឃោរឃៅ និងការទន្ទ្រានកាន់កាប់ប្រទេសកម្ពុជា ។

ទំនាក់ទំនងជិតស្និទ្ធរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាមជាឧបករណ៍ឃោសនាដ៏មានឥទ្ធិពលសម្រាប់ឲ្យខ្មែរក្រហមជ្រើសរើសទ័ពឡើងវិញ ។ ខ្មែរក្រហមទទួលបានការគាំទ្រពីសមាជិកអាណិកជនខ្មែរនៅបរទេស និងខ្មែរដែលរត់ទៅបរទេសក្រោយរបបខ្មែរក្រហម ដែលបានអះអាងពីអត្តសញ្ញាណនិងភាពស្របច្បាប់ ដើម្បីធ្វើការប្រឆាំងនឹងវត្តមានរបស់វៀតណាមនៅកម្ពុជា ។

ដោយមានអនុសញ្ញាសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ១៩៩១ រូបរាងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងប្រទេសកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន និងការបោះឆ្នោតដែលរៀបចំដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ គណបក្សនេះត្រូវបានរិះគន់យ៉ាងខ្លាំងអំពីចំណងមិត្តភាពជាមួយវៀតណាម ពីក្រុមបក្សប្រឆាំងដទៃទៀតនិងប្រជាជនខ្មែរនៅបរទេស ។ ផ្ទុយទៅវិញ គណបក្សប្រជាជនកម្ពុជាបន្តអះអាងពីភាពត្រឹមត្រូវរបស់ខ្លួន ស្តីពីការរំដោះនិងការបន្តការការពារប្រជាជនពីការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម (បន្ទាប់ពីពួកគេធ្លាក់ពីអំណាច) ។ ជម្លោះទាំងនេះជារឿយៗបានកើតឡើងចំពោះទីតាំងដែលពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាក់ស្តែងមានការពិភាក្សាស្តីពីការកប់ចំណែកឆ្អឹងដែលសេសសល់នៅជើងឯក (គណបក្សប្រជាជនអះអាងថាភ័ស្តុតាងគួរតែរក្សាទុកតែសម្តេចព្រះ នរោត្តម សីហនុ ចង់ជំរុញឲ្យមានការផ្សះផ្សា និងថាព្រលឹងរបស់

អ្នកស្ដាប់គួរតែបានស្ងប់ស្ងាត់) និងដែនទីលលាដ៏ក្បាលនៅទួលស្លែង (ត្រូវបានគេយកចេញកាលពីឆ្នាំ ២០០៣) ។ សេចក្ដីថ្លែងការណ៍ពីការផ្សះផ្សាថ្មីបានលេចឡើងព្រមគ្នា ជាមួយនឹងដំណើរការសន្តិភាព ដែលនាំទៅរកការផ្លាស់ប្ដូរដ៏សំខាន់មួយ ។ ឧទាហរណ៍ ការរៀបរាប់ពីរបបកម្ពុជាប្រជាធិបតេយ្យលែង មាននៅក្នុងកម្មវិធីបង្រៀនរបស់សាលា ។ ព្រមជាមួយគ្នានេះ គេមិនសូវចាប់អារម្មណ៍ពីសេចក្ដីថ្លែង ការណ៍អំពីសិទ្ធិមនុស្សទេ ដោយសារគេផ្អែកលើទស្សនៈព្រះពុទ្ធសាសនា ទោះបីជាសេចក្ដីថ្លែងនេះត្រូវ បានបញ្ចូលក្នុងកតិកាសញ្ញាសន្តិភាពទីក្រុងប៉ារីស និងរដ្ឋធម្មនុញ្ញថ្មី ដែលគាំទ្រដោយអ៊ុនតាក់ក៏ដោយ ។

## ការយល់ឃើញតាមទស្សនៈព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាបានដើរតួយ៉ាងសំខាន់ក្នុងដំណើរការផ្សះផ្សា ។ នៅពេលដែលសាសនាត្រូវបាន ប្រតិបត្តិឡើងវិញ ប្រជាជនកម្ពុជាទូទាំងប្រទេសចាប់ផ្ដើមកសាងព្រះវិហារនិងរៀបចំពិធីបុណ្យសាសនា ផ្សេងៗ ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាចាត់ទុកព្រះពុទ្ធសាសនាជាស្ថាប័នមួយដែលគេអាចផ្សព្វផ្សាយ គោលនយោបាយគណបក្ស ហើយការបំផ្លិចបំផ្លាញដោយខ្មែរក្រហមជានិមិត្តរូបនៃបទល្មើសរបស់របប កម្ពុជាប្រជាធិបតេយ្យ ។ ទោះជាយ៉ាងនេះក្ដី ព្រះពុទ្ធសាសនាក៏បានផ្ដល់នូវទស្សនៈស្ដីពីព្រឹត្តិការណ៍ ដែលបានកើតឡើងតាមរយៈកម្មផល បុណ្យបាប ដែលមនុស្សបានប្រព្រឹត្ត ។ វាក៏បានបង្ហាញពីមធ្យោ បាយដោះស្រាយរឿងអតីតកាលតាមរយៈការធ្វើសមាធិនិងការអធ្យាស្រ័យផងដែរ ។

ដូច្នេះ ពេលនិយាយដល់អ្នកភូមិម្នាក់ដែលបាននាំ ស្រួន ទៅសម្លាប់ ឆ្លាត ដែលជាពុទ្ធសាសនិក បាននិយាយថា ខ្ញុំនៅគិតដល់ការសងសឹក ប៉ុន្តែខ្ញុំមិនដឹងបញ្ឈប់គំនិតនេះតាមរបៀបណាទេ ។ យើងមិន គួរមានគំនិតបែបនេះទេ ពុំនោះបញ្ហានឹងរីកកាន់តែធំនិងបន្តយូរទៅមុខទៀត ។ យើងគួរធ្វើជាមនុស្ស ដែលចេះគិត និងប្រព្រឹត្តតាមធម៌ព្រះពុទ្ធ ។ មនុស្សដែលចង់សងសឹកនិងបង្កភាពសោកសៅដល់សង្គម គឺជាជន្លូវសង្គម ។ តែខ្ញុំនៅតែគិតដល់ការសងសឹកចំពោះអ្នកសម្លាប់បងប្រុសខ្ញុំដែលបានកត់ឈ្មោះគាត់ បញ្ជូនឡើងរថយន្តយកទៅសម្លាប់ ហើយអ្នកទាំងនោះសុទ្ធតែនៅរស់ក្នុងភូមិខ្ញុំនេះតែម្ដង ។ សព្វថ្ងៃខ្ញុំនៅ តែចង់សងសឹក ខ្ញុំនៅតែតាមដានពីបញ្ហាខ្មែរក្រហម ។ ប៉ុន្តែខ្ញុំមិនដឹងធ្វើម៉េច ព្រោះរដ្ឋាភិបាលក៏ហាម ឃាត់រឿងនេះដែរ ។

ដើម្បីស្វែងយល់ការរៀបរាប់របស់ ឆ្លាត ក៏ដូចជាការឆ្លើយតបរបស់គាត់ចំពោះអំពើហិង្សាក្នុង អតីតកាល យើងត្រូវវិភាគការរៀបរាប់របស់គាត់ ។

ទស្សនៈព្រះពុទ្ធសាសនាទាក់ទងយ៉ាងសំខាន់ទៅនឹងការឆ្លើយតបទាំងនេះ ។ ដូច្នេះ ជួនកាលប្រជា ជនខ្មែរនិយាយថា ពួកខ្មែរក្រហមនឹងទទួលកម្មផលរបស់គេ ។ ប្រជាជននិយាយថា "ធ្វើល្អបានផលល្អ ធ្វើអាក្រក់បានផលអាក្រក់" ។ ទស្សនៈព្រះពុទ្ធសាសនាពន្យល់ថា ហិង្សាមានប្រភពមកពីអវិជ្ជានិង

តណ្ហា ។ ប្រសិនបើអំពើហឹង្សាកើតឡើងជាក់ស្តែង នោះផលវិបាកក៏កើតឡើងរយៈពេលយូរដែរ ។ ម្យ៉ាងវិញទៀត អំពើហិង្សាអាចនាំឲ្យអ្នកដទៃចង់សងសឹកនឹងអ្នក ហើយការធ្វើបាបអ្នកដទៃ ចាត់ទុកជាបាបកម្មដែលនាំឲ្យបាត់បង់បុណ្យកុសលនៅជាតិក្រោយ ។

លើសពីនេះ ការជាប់ជំពាក់ទៅនឹងហិង្សានិងកំហឹងធ្វើឲ្យបាត់បង់ភាពស្ងប់ខាងផ្លូវចិត្តរបស់ប្រជាជនកម្ពុជា រួមទាំងទំនាក់ទំនងសង្គមនិងផ្លូវកាយ ។ អារម្មណ៍ខឹងសម្បារដែលបង្កើតជាការរំខានដល់ភាពស្ងប់ទាំងផ្លូវកាយនិងផ្លូវចិត្តគឺជាសញ្ញារំខានដែលធ្វើឲ្យមនុស្សមានអារម្មណ៍ឈឺចាប់ មិនស្រួលខ្លួន វិលមុខ ឬក្តៅខ្លួន ។ កម្តៅនៃកំហឹងទៅលើសម្ពាធផ្លូវអារម្មណ៍ជំរុញឲ្យចិត្តមនុស្សធ្វើសកម្មភាព ។ ការឡើងកម្តៅនិងកំហឹងបង្ហាញពីសភាពមិនស្ងប់ ដែលជាប់ទាក់ទងនឹងអតីតកាល ដែលវាមិនគ្រាន់តែជាការរំខានក្នុងចិត្តទេ តែវាថែមទាំងជាសញ្ញានៃការឈឺចាប់ក្នុងសង្គម ដែលបង្កប់អត្ថន័យនយោបាយនិងសីលធម៌ទៀតផង ។

ក្រៅពីការថែងពីឫសគល់នៃហិង្សានិងផលវិបាក ព្រះពុទ្ធសាសនាបានប្រាប់ពីមធ្យោបាយកម្ចាត់ចោលទង្វើបែបនេះតាមរយៈមជ្ឈិមប្បដិបទា (ការប្រតិបត្តិតាមផ្លូវកណ្តាល) ។ ក្នុងផ្លូវពុទ្ធចក្រ ប្រជាជនខ្មែរត្រូវជំរុញឲ្យប្រតិបត្តិសីល៥ ដែលសីលទីមួយគឺការវៀរចាកការសម្លាប់ ។ ព្រះសង្ឃទេសនាថា យើងត្រូវរៀនគ្រប់គ្រងនិងបំបាត់កំហឹងរបស់ខ្លួន ដែលកើតចេញពីអវិជ្ជានិងតណ្ហា ហើយវានាំទៅរកហិង្សានិងការឈឺចាប់ ។ ក្នុងទ្រឹស្តីព្រះពុទ្ធសាសនា វិធីដោះស្រាយកំហឹងគឺត្រូវស្គាល់ប្រភពរបស់វាឲ្យបានច្បាស់លាស់ និងត្រូវបំបាត់ចោលកំហឹងដែលបានកើតឡើង ហើយអ្វីៗនៅក្នុងលោកនេះមិនឋិតថេរទេ ។ អ្នកដែលនៅតែប្រព្រឹត្តដោយអវិជ្ជានឹងទទួលការឈឺចាប់ពីទង្វើរបស់ខ្លួន ដូចជាស្រមោលអន្ទោលតាមប្រាណ ហើយនឹងទទួលរងការឈឺចាប់គ្រប់ជាតិ ។

បើព្រះពុទ្ធសាសនាថែងពីយុត្តិធម៌សម្រាប់ជនរងគ្រោះ វាក៏បញ្ជាក់ដែរថា ការឈឺចាប់របស់អ្នកទាំងនោះគឺជាផលនៃអំពើបាបក្នុងអតីតកាល ។ អ្នកខ្លះយល់ថា អ្វីដែលបានកើតឡើងគឺត្រូវតាមព្រះពុទ្ធទំនាយ ។ អ្នកទាំងនោះបានទស្សន៍ទាយពីរយៈពេលដែលសត្រូវ ឬវណ្ណៈក្រីក្រនៃសង្គមខ្មែរឡើងកាន់អំណាច ដែលផ្លាស់ប្តូរសណ្តាប់ធ្នាប់សង្គមឲ្យក្លាយទៅជាការល្មើសលើព្រះពុទ្ធសាសនា ទុរភិក្ស និងការស្លាប់ ។ ពាក្យស្លោករបបកម្ពុជាប្រជាធិបតេយ្យមួយដែលទាក់ទងនឹងការមិននិយាយស្តី "ដាំដើមគ" ដែលទំនងជាដកស្រង់ចេញពីការទស្សន៍ទាយរបស់អ្នកនិពន្ធ ពិន យ៉ាថៃ ដែលពន្យល់ថា ព្រះពុទ្ធសាសនាដែលមានអាយុកាលជាង១៩សតវត្សរ៍បានទស្សន៍ទាយថា ប្រទេសនេះនឹងត្រូវផ្លាស់ប្តូរទាំងស្រុង "មានផ្ទះអត់មនុស្សនៅ មានផ្លូវអត់មានមនុស្សដើរ មនុស្សអវិជ្ជាប្រឆាំងនឹងអ្នកចេះដឹង ទមិឡនឹងកាន់អំណាចផ្តាច់ការសម្លាប់បព្វជិត" ។ ប៉ុន្តែប្រជាជននឹងត្រូវបានជួយសង្គ្រោះ ប្រសិនបើគាត់ដាំដើមគ ដែលមានន័យថាមិនចេះនិយាយស្តី ។ ប្រស្នានេះប្រែថា មានតែអ្នកដែលគថ្លង់ទេដែលអាចរួចផុតពី

សេចក្ដីស្លាប់នៅអំឡុងសម័យកាលកលិយុគនេះ ។ ធ្វើគ ធ្វើថ្លង់ ។ ឥឡូវខ្ញុំដឹងថាវាជាមធ្យោបាយសង្គ្រោះជីវិត ។ ធ្វើពុតជាគថ្លង់ កុំនិយាយអ្វីទាំងអស់ កុំស្ដាប់អ្វីទាំងអស់ កុំយល់អ្វីទាំងអស់ ។

ក្នុងផ្លូវអាណាចក្រ ទំនាយនេះបានធ្វើឲ្យខ្មែរមានទស្សនៈពីរ គឺភាពបរិសុទ្ធ និងភាពពិសពុល ដែលមានភាពផ្ទុយគ្នារវាងព្រះពុទ្ធ និងមារ ធម៌និងអធម៌ សណ្ដាប់ធ្នាប់និងភាពចលាចល ការស្រុះស្រួលនិងការបែកបាក់ ។

ដើម្បីស្វែងយល់ពីនយោបាយចងចាំក្នុងប្រទេសកម្ពុជាឲ្យកាន់តែច្បាស់ យើងមិនត្រឹមសម្លឹងមើលតែទៅលើរចនាសម្ព័ន្ធនៃការពិភាក្សាថ្នាក់ជាតិប៉ុណ្ណោះទេ តែក៏ត្រូវមើលទៅលើការពិភាក្សាថ្នាក់សហគមន៍ និងថ្នាក់ក្រោមៗផងដែរ ។ ក្នុងឧទាហរណ៍ជាច្រើនយើងឃើញមានភាពដូចគ្នា ។ ប៉ុន្តែវាក៏មានចំណុចខុសគ្នាសំខាន់ៗដែរ ដូចជាការពិភាក្សារបស់អ្នកកាន់ព្រះពុទ្ធសាសនានៅតាមសហគមន៍ក្នុងអំឡុងពេលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាជាដើម ។

ការលេចចេញម្ដងទៀតនេះគឺដោយសារព្យុហយាត្រាសន្តិភាព របស់សម្ដេចព្រះមហាឃោសនន្ទា នៅដើមទសវត្សរ៍៩០ ដែលអះអាងពីការរស់ឡើងវិញនៃព្រះសង្ឃ និងព្រះធម៌ (តាមរយៈការដាំកូនឈើ និងការប្រមូលផ្ដុំធ្វើធម្មយាត្រា) ដែលមានសារសំខាន់សម្រាប់បោសសម្អាតឧបទ្រពចង្រៃនៅក្នុងប្រទេសកម្ពុជា និងការបំបាត់ចោលកំហឹង (ដោយការបាចទឹកមន្តរំដោះគ្រោះ) និងការចង់បានសន្តិភាពគឺជានិមិត្តរូបនៃធម្មយាត្រាដែលឆ្លងកាត់គ្រប់តំបន់ក្នុងប្រទេសកម្ពុជា រួមទាំងតំបន់សង្គ្រាម បច្ចុប្បន្ននិងអតីតកាល ។

ពេលថ្មីៗនេះ ការពិភាក្សាតាមរយៈអ្នកកាន់ព្រះពុទ្ធសាសនាមានភាពមិនចុះសម្រុងជាមួយនឹងសេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិមនុស្សជាសាកល ដែលផ្សារភ្ជាប់ទៅនឹងវិធីនៃការចងចាំពីអតីតកាលមួយគឺការផ្ដួចផ្ដើមបង្កើតឲ្យមានសាលាក្ដី ។ ខណៈដែលព្រះពុទ្ធសាសនាលើកកម្ពស់ការយល់ដឹងពីអតីតកាលដែលជាអំណះអំណាងសម្រាប់ការបង្កើតសាលាក្ដី ពុទ្ធសាសនាក៏អះអាងពីសារសំខាន់នៃការបំភ្លេចអតីតកាល បំបាត់កំហឹង និងចំណងទាំងឡាយដែរ ។ ផ្អែកលើអ្វីដែលបានលើកឡើង គោលគំនិតទាំងនេះផ្ទុយពីការអះអាង ដែលថាសាលាក្ដីនឹងជំរុញឲ្យប្រជាជនខ្មែរទទួលបានយុត្តិធម៌ ឲ្យគេអាចព្យាបាលជំងឺផ្លូវចិត្ត និងដើម្បីពង្រឹងការអនុវត្តច្បាប់នៅកម្ពុជា ។ សេចក្ដីថ្លែងការណ៍ទាំងនេះគឺផ្សារភ្ជាប់ទៅនឹងគំរូរបស់តុលាការបស្ចិមប្រទេសតាមគោលគំនិតនៃការអត់ឱនរបស់គ្រិស្តសាសនា និងដំណើរការផ្លូវចិត្តជាសកល ។

## នយោបាយនៃការចងចាំក្នុងពេលបច្ចុប្បន្ន

រឿងនេះត្រូវបានសរសេរឡើងនៅពេលបច្ចុប្បន្ន ដោយសារប្រទេសកម្ពុជាបន្តដោះស្រាយភាពសាំញ៉ាំនៃអតីតកាលនៅពេលដែលសាលាក្ដីមួយចាប់ផ្ដើម ។ នៅត្រង់ចំណុចនៃប្រវត្តិសាស្ត្រកម្ពុជា តើ

នេះជាវិធីសមស្របដើម្បីដោះស្រាយបញ្ហាអតីតកាលដែរឬទេ? តើសាលាក្តីគួរតែបន្ថែមកិច្ចការស្វែងរកយុត្តិធម៌និងការចងចាំ ដូចជាគណៈកម្មការស្វែងរកការពិត ឬការដោះស្រាយតាមរយៈពិធីធ្វើបុណ្យតាមបែបព្រះពុទ្ធសាសនាដែរឬទេ? ឬ តើប្រជាជនគួរតែបំបាត់កំហឹងរបស់គេ បំភ្លេចអតីតកាលនិងគិតពីអនាគតឬទេ?

នៅពេលខ្ញុំគិតដល់សំណួរមួយនេះ ខ្ញុំចង់ដឹងថាមនុស្សដូច ឆ្លាត អាចនឹងឆ្លើយតបយ៉ាងដូចម្តេច ។ ខ្ញុំមិនអាចសួរគាត់សោះ ។ ពេលចុងក្រោយដែលខ្ញុំបានជួបគាត់នៅរដូវប្រាំង ឆ្នាំ២០០៣ គាត់មានរូបរាងស្គម ហើយឈឺជាញឹកញាប់ ។ គាត់បានពន្យល់ដោយស្នាមញញឹមថា គាត់មានមេរោគក្នុងខ្លួនដែលប្រតិកម្មនឹងថ្នាំដោយក្តាប់ដៃ ដើម្បីបង្ហាញពីរបៀបដែលមេរោគធ្វើទុក្ខរាល់ពេលគាត់លេបថ្នាំម្តងៗ ។ យើងបានជជែកគ្នាពីអតីតកាលមុនពេលគាត់ហូបបាយល្ងាចជាមួយមិត្តភក្តិម្នាក់ទៀតនិងកូនប្រុសរបស់គាត់ ។ ច្រើនខែកន្លងមក ខ្ញុំបានទទួលដំណឹងពីមិត្តភក្តិរបស់គាត់ថា ឆ្លាត សម្រាកនៅមន្ទីរពេទ្យរង់ចាំសេចក្តីស្លាប់ប៉ុណ្ណោះ ។ គាត់មានផ្ទុកមេរោគអេដស៍ ។ ប៉ុន្មានថ្ងៃក្រោយមកក៏ស្លាប់ ។

ខ្ញុំគិតថា ឆ្លាត ចង់បានសាលាក្តីមួយ ទោះបីជាខ្ញុំដឹងហើយថាគាត់ព្រួយបារម្ភពីអំពើពុករលួយនៃប្រព័ន្ធតុលាការកម្ពុជា ការលាក់ពុតរបស់សហគមន៍អន្តរជាតិ និងការដែលមិនអាចទៅជួបជាមួយកម្មាភិបាលដែលបានបញ្ជូនបងប្រុសគាត់ទៅសម្លាប់នៅវត្តភ្នំប្រុសក៏ដោយ ។ ខ្ញុំស្រមៃដល់ចម្លើយដែលគាត់ឆ្លើយក្នុងទីងងឹត មុខបាំងដោយផ្សែងបារី ហើយភ្លើងបារីដែលកំពុងឆេះប្រៀបដូចការចងចាំរបស់គាត់ដែលក្រោយមកក្លាយជាផេះផង់ ។

អាឡិចហ្សេនឌឺ ហ៊ិនតុន